ផលិតចងក្រងដោយ NSW HEALTH DEPARTMENT
multicultural communication
Khmer
June 2003
[DOH-7130]

# ជម្ងឺអុតក្តាម
## Hand, Foot and Mouth Disease

### តើជំងឺអុតក្តាមជាអ្វី?

ជាទូទៅ ជម្ងឺអុតក្តាម ជាជម្ងឺស្រាលមួយដែលបណ្តាលមកពីវីរុសម្យ៉ាងហៅថាកុកសាគីវីរុស (coxsackievirus) ឬអង់តេរ៉ូវីរុស (enterovirus) ។ វាមិនមែនជាជម្ងឺធ្ងន់ធ្ងរ ហើយមិនទាក់ទងជាមួយជម្ងឺរបស់សត្វពាហនៈ ដែលហៅថា ជម្ងឺអុតក្តាមសត្វនោះទេ។ ជម្ងឺនេះកើតឡើងញឹកញាប់លើកូនក្មេងអាយុក្រោម ១០ ឆ្នាំ ប៉ុន្តែ ជម្ងឺនេះក៏អាចកើតនៅលើក្មេងអាយុច្រើនជាងនេះនិងមនុស្សពេញវ័យផងដែរ ។

### តើវាអាចប៉ះពាល់ដល់អ្នកយ៉ាងដូចម្តេច?

ការចំលងរបស់ coxsackievirus ឬ enterovirus អាចកើតឡើងដោយគ្មានរោគសញ្ញាសោះ ឬ មានសញ្ញាតិចតួចប៉ុណ្ណោះ ។ នៅពេលដែលមានរោគសញ្ញាកើតឡើង រោគសញ្ញាទាំងនោះ រួមមានពងលើស្បែក ដែលចាប់ផ្តើមដោយចំនុចតូចក្រហម ហើយក្រោយមកក្លាយជាដំបៅ ។ ពងបែកនេះលេចឡើងនៅផ្នែកខាងក្នុងថ្ពាល់, អញ្ចាញធ្មេញ និងនៅលើចំហៀងអណ្តាត ក៏ដូចជានៅលើដៃនិងជើងផងដែរ។ ចំពោះទារក ជួនកាលពងបែកអាចមើលឃើញនៅក្នុងកន្លែងស្លៀកកន្ទប ។ ជា ទូទៅពងបែកនឹងបាត់ទៅវិញក្នុងរយៈពេល ៧-១០ ថ្ងៃ ។ ជួនកាលក្មេងអាចមានក្តៅខ្លួនតិចតួច ឈឺបំពង់ក, អស់ កំលាំង, ស្លេកស្លាំង និង អាចមិនឃ្លានបាយរយៈពេលមួយ ឬពីរថ្ងៃ ។ ជារឿងកំរដែលមេរោគ coxsackievirus អាចបណ្តាលឲ្យមានជំងឺផ្សេងៗទៀត ដែលអាចប៉ះពាល់ដល់បេះដូង ខួរក្បាល ឬ ស្រោមខួរក្បាល (រលាកស្រោមខួរ) សួត ឬ ភ្នែក ។

### តើជម្ងឺនេះមានលក្ខណៈទូទៅយ៉ាងដូចម្តេច?

ជម្ងឺអុតក្តាម ជាជម្ងឺមួយដែលកើតឡើងជាធម្មតានិងការរាតត្បាតអាចកើតឡើងចំពោះក្រុមកូនក្មេង, ជាឧទាហរណ៍នៅក្នុងមណ្ឌលថែរក្សាកូនក្មេង ។

### តើជម្ងឺនេះឆ្លងរាលដាលយ៉ាងដូចម្តេច?

ជាទូទៅ ជម្ងឺអុតក្តាមនេះឆ្លងរាលដាលពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត តាមរយៈការប៉ះពាល់គ្នា។ វីរុសឆ្លងចូលទៅក្នុងមាត់នៃជនណាម្នាក់ តាមរយៈដៃដែលប្រឡាក់លាមកជនដែលមានផ្ទុកមេរោគ។ ជម្ងឺនេះក៏ឆ្លងតាមរយៈទឹកមាត់និងទឹកចំហាយចេញពីប្រព័ន្ធផ្លូវដង្ហើម និងតាមរយៈការប៉ះពាល់ដោយផ្ទាល់ជាមួយទឹករងៃនៃ ពងបែកនោះ។ ជាទូទៅជម្ងឺនេះត្រូវការពេលរវាង ៣-៥ ថ្ងៃ បន្ទាប់ពីការប៉ះពាល់ជាមួយអ្នកផ្ទុកមេរោគ មុនពេលពងបែកនោលេចចេញឡើង ។ កាលណានៅមានទឹករងៃក្នុងពងបែកនោះ ពងបែកទាំងនោះនៅតែមានមេរោគ ដែលអាចចំលងទៅអ្នកដទៃទៀតបាន។ វីរុសនៅតែអាចមានក្នុងលាមករហូតដល់ពេលច្រើនអាទិត្យ ។

### តើគេព្យាបាលជម្ងឺនេះយ៉ាងដូចម្តេច?

ជាធម្មតាគេពុំចាំបាច់ព្យាបាលជម្ងឺនេះទេ ។ ថ្នាំ Paracetamol នឹងបន្ថយការក្តៅខ្លួននិងភាពមិនស្រួលខ្លួន។ មិនត្រូវឲ្យកុមារ លេបថ្នាំអាស្ពីរីនទេ ។ បើសិនជាឈឺក្បាលខ្លាំង ឬ នៅតែក្តៅខ្លួន សូមទៅពិគ្រោះយោបល់ជាមួយគ្រូពេទ្យ។

### តើគេបង្ការយ៉ាងដូចម្តេច?

- អនាម័យល្អគឺជាការការពារដ៏ប្រសើរបំផុត : លាងដៃដោយទឹកនិងសាប៊ូក្រោយចេញពីបង្គន់, មុនបរិភោគ, បន្ទាប់ពីជូតសំបោរ និងក្រោយពីផ្លាស់ប្តូរកន្ទប ឬសំលៀកបំពាក់កខ្វក់ ។
- ជៀសវាងការប្រើចូលទ្បុកទ្បុំគ្នានូវពែង, សំភារៈសំរាប់ហូបចុក, សំភារៈអនាម័យផ្ទាល់ខ្លួនផ្សេងៗ (ឧទាហរណ៏ កន្សែងពោះគោ, កន្សែងជូតមុខ និងច្រាស់ដុសធ្មេញ) និង សំលៀកបំពាក់ (ជាពិសេសស្បែកជើងនិងស្រោមជើង)។
- ត្រូវបោកគក់សំលៀកបំពាក់កខ្វក់ឲ្យបានត្រឹមត្រូវ។
- ត្រូវគ្របមាត់និងច្រមុះនៅពេលក្អក និង កណ្តាស់ ។ ជូតសំបោរនិងជូតមាត់ដោយក្រដាស អនាម័យ, បោះចោលក្រដាសអនាម័យដែលប្រើរួចហើយបន្ទាប់មកត្រូវលាងដៃរបស់អ្នក ។

### តើគេគ្រប់គ្រងទប់ស្កាត់ការឆ្លងរាលដាលនៃជម្ងឺនេះយ៉ាងដូចម្តេច?

កូនក្មេងដែលមានជម្ងឺអុតក្តាម មិនគួរចូលសាលា ឬ មណ្ឌលថែរក្សាក្មេង រហូតដល់ពងបែករបស់កុមារបានស្ងួតក្រៀម ។

គប្បីរាយការណ៏អំពីជម្ងឺនេះ ទៅឲ្យនាយកមជ្ឈមណ្ឌលថែរក្សាក្មេង ឬ នាយកសាលារៀនបានដឹង។

ព័ត៌មានបន្ថែម- **Public Health Units in NSW**

ចំពោះព័ត៌មានបន្ថែម សូមទាក់ទងវេជ្ជបណ្ឌិត មន្ទីរសុខភាពសាធារណ:តាមតំបន់ ឬមណ្ឌលសុខភាពក្នុងសហគមន៏របស់លោកអ្នក។ សូមមើល នៅត្រង់កន្លែង ‘NSW Government’ នៅផ្នែកខាងមុខនៃសៀវភៅ White Pages។

| | |
|---|---|
| **Metropolitan Areas** | |
| Central Sydney | 9515 3180 |
| South Eastern Sydney | 9382 8333 |
| Northern Sydney | 9477 9400 |
| South Western Sydney | 9828 5944 |
| Western Sydney | 9840 3603 |
| Wentworth | 4734 2022 |
| **Rural Areas** | |
| Central Coast | 4349 4845 |
| Mid North Coast | 6588 2750 |
| Mid Western | 6339 5548 |
| Hunter | 4924 6477 |
| Illawarra | 4255 2200 |
| New England | 6766 2288 |
| Northern Rivers | 6620 7500 |

| | |
|---|---|
| Macquarie | 6841 2216 |
| Southern | 4827 3428 |
| Greater Murray | 6021 4799 |
| Far West | (08) 8080 1499 |

**NSW Department of Health**
73 Miller Street
North Sydney NSW 2059
Tel. (02) 9391 9000
Fax. (02) 9391 9101
TTY. (02) 9391 9900

NSW Health website
www.health.nsw.gov.au